ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
feel the warmth

ក្រសួងទេសចរណ៍
លេខ ៥៤៩ សជណ.

សេចក្តីជូនដំណឹង
ស្តីពីការបើកដំណើរការព្រឹត្តិការណ៍ «ភូមិហ្វ្រង់កូហ្វូនី-Village de la Francophonie» ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៦ នៅរាជធានីភ្នំពេញ

ក្រសួងទេសចរណ៍ មានកិត្តិយសសូមជម្រាបជូនក្រសួង ស្ថាប័នសាធារណៈ វិស័យឯកជន បណ្តាញសារព័ត៌មាន ភ្ញៀវទេសចរជាតិ-អន្តរជាតិ និងសាធារណជនទាំងអស់ឱ្យបានជ្រាបថា ក្នុងស្មារតីអបអរសាទរព្រះរាជាណាចក្រកម្ពុជាទទួលធ្វើជាម្ចាស់ផ្ទះរៀបចំ **«កិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០»** ក្រសួងទេសចរណ៍សហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងកិច្ចការនារី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋបាលរាជធានីភ្នំពេញ និងក្រសួង ស្ថាប័នពាក់ព័ន្ធ នឹងបើកដំណើរការ **«ភូមិហ្វ្រង់កូហ្វូនី»** ក្រោមប្រធានបទ **«ស្នាមញញឹមខ្មែរ ស្នាមញញឹមហ្វ្រង់កូហ្វូនី»** ចាប់ពីថ្ងៃទី១៣ **ដល់ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៦ នៅបរិវេណសួនច្បារវត្តបទុមវតី រាជធានីភ្នំពេញ**។

ពិធីបើកសម្ពោធជាផ្លូវការនឹងប្រព្រឹត្តទៅនាព្រឹកថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៦ ក្រោមអធិបតីភាពដ៏ខ្ពស់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត** និង**លោកជំទាវ** Louise Mushikiwabo **អគ្គលេខាធិការ នៃអង្គការអន្តរជាតិហ្វ្រង់កូហ្វូនី** (OIF)។

ជាមួយគ្នានេះ សម្រាប់រយៈពេល៥ថ្ងៃ ភូមិហ្វ្រង់កូហ្វូនីនឹងបើកទទួលស្វាគមន៍គណៈប្រតិភូ ភ្ញៀវទេសចរជាតិ-អន្តរជាតិ និងសាធារណជន ចាប់ពីម៉ោង១០និង០០នាទី ព្រឹក រហូតដល់ម៉ោង ៩និង០០នាទី យប់ ដោយមានកម្មវិធីចម្រុះប្រកបដោយភាពសម្បូរបែប និងមានភាពរស់រវើក ក្នុងនោះរួមមាន៖

១- តំបន់ពន្លាជាតិ ដែលមានការតាំងបង្ហាញអំពីអត្តសញ្ញាណជាតិ វប្បធម៌ ប្រពៃណី សិល្បៈ សក្តានុពលទេសចរណ៍ និងសមិទ្ធផលនានារបស់ប្រទេស/រដ្ឋ/តំបន់ដែលជាសមាជិកអង្គការ OIF និងស្ថាប័នចំណុះអង្គការ OIF ចំនួន ៧៣ ទីតាំងពន្លា។

២- ការរៀបចំសន្និសីទ និងកិច្ចពិភាក្សានានា មានចំនួនប្រមាណ ៤០ កម្មវិធី។

៣- ការសម្តែងសិល្បៈ និងវប្បធម៌របស់បណ្តាប្រទេសសមាជិកអង្គការ OIF និងទស្សនីយភាពសិល្បៈរបស់កម្ពុជា ដែលរៀបចំដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដែលមានប្រមាណជាង ៥០ កម្មវិធី។

៤- ការតាំងពិព័រណ៌ទូទៅ ដោយមានការចូលរួមពីបណ្តាប្រទេសអង្គការ OIF ក្រសួង ស្ថាប័នសាធារណៈ រដ្ឋបាលរាជធានី-ខេត្ត សមាគម អង្គការជាតិ-អន្តរជាតិ និងវិស័យឯកជន សរុបចំនួន ១៣០ ស្តង់។

៥- ភូមិអាហារហ្វ្រង់កូហ្វូនី ដែលមានការបង្ហាញ និងផ្សព្វផ្សាយម្ហូបអាហារ កេសជ្ជៈ និងផលិតផលម្ហូបអាហារអត្តសញ្ញាណរបស់កម្ពុជា និងបណ្តាប្រទេសក្នុងសហគមន៍ហ្វ្រង់កូហ្វូនី សរុបចំនួន ៣០ ស្តង់ និងសកម្មភាពអមជាច្រើនទៀត។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ក្រសួង ស្ថាប័នសាធារណៈ វិស័យឯកជន បណ្តាញសារព័ត៌មានភ្ញៀវទេសចរជាតិ-អន្តរជាតិ និងសាធារណជនទាំងអស់ ជ្រាបជាព័ត៌មាននិងអញ្ជើញចូលរួមព្រឹត្តិការណ៍ **«ភូមិហ្វ្រង់កូហ្វូនី»** ឱ្យបានច្រើនកុះករ។ឈ

ថ្ងៃព្រហស្បតិ៍ ៣កើត ខែកត្តិក ឆ្នាំមមីឯកស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៦

ជីឡូត៍លេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Website: www.tourism.gov.kh
Telegram: t.me/motgovkh
ទូរស័ព្ទ៖ +៨៥៥ ២៣ ៨៨៩ ៨៩៨
E-mail: admin@tourism.gov.kh